# ទស្សនវិជ្ជានយោបាយ : គំនិតនិងចលនាជាតិនិយម

( POLITICAL PHILOSOPHY : Nationalist Ideas and Movements )

*ដោយ* : **បណ្ឌិត ភ្លាន់ ធុល**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១- សេចក្តីផ្តើម

*អវិជ្ជាគឺជាការមិនយល់ មិនស្គាល់ពីធម្មជាតិពិតរបស់វត្ថុ ឬធម្មជាតិពិតនៃអត្ថិភាពរបស់ខ្លួនឬអាចនិយាយបានម្យ៉ាងទៀតថា មិនមើលឃើញវត្ថុនានា ទៅតាមធម្មជាតិពិតរបស់វា។ ដោយសារ មនុស្សមិនមើលឃើញវត្ថុនានាទៅតាម ធម្មជាតិពិតរបស់វានេះហើយ ទើបបានជាពួកគេមានសេចក្តីប្រាថ្នាច្រើនមិនចេះចប់ ដែលធ្វើឱ្យពួកគេនឿយហត់ក្នុងការដេញតាម គ្មានម៉ោង, គ្មានពេល, និងគ្មានថ្ងៃឈប់សម្រាក់ពេញមួយជីវិត។ អវិជ្ជា នាំឱ្យមនុស្ស មានគំនិតប្រកាន់ខ្ជាប់ថា អ្វីៗ ទោះជារបស់ក្នុងខ្លួនក្តី ឬរបស់ក្រៅខ្លួនក្តី ដូចជា ដៃ, ជើង, ខ្លួនប្រាណ, ឡាន, ផ្ទះសម្បែង, លុយកាក់, មាសប្រាក់, កូន, ប្រពន្ធ-ប្តី, គោ, ក្របី, សេះ, ដំរី...ល។ សុទ្ធតែ**ជារបស់ខ្លួន**។ គំនិតថា អ្វីៗទាំងអស់ សុទ្ធតែ **ជារបស់ខ្លួន** នេះនាំឱ្យមនុស្សបង្កើតនូវពាក្យ **កម្មសិទ្ធិ** ដើម្បីសម្គាល់ថា វត្ថុណាមួយ គឺជា **កម្មសិទ្ធិរបស់ខ្លួន** ដូចជា **របស់ខ្ញុំ*** (my), ***របស់គាត់/ របស់គេ*** (his/her), ***របស់យើង*** (our), ***របស់ពួកគេ*** (their), ***របស់វា*** (its) *ជាដើមនេះៗ ឧទាហរណ៍ គោនេះ ឬផ្ទះនោះ គឺជារបស់ពួកយើង ឬជារបស់ខ្ញុំជាដើម្បី។ តាមសច្ចភាព តើមានរបស់អ្វីខ្លះដែលជារបស់បុគ្គលណាម្នាក់យ៉ាងផ្តាច់មុខនោះ? ឧទាហរណ៍ រតនាមានលុយ២៩០០$ មានន័យថា លុយ២៩០០$ នេះគឺជាលុយកម្មសិទ្ធិ របស់នាង គ្មានអ្នកណាម្នាក់ហ៊ានយកវា ពីនាងឡើយ។ រតនាបានយកលុយ ២៩០០$ នេះ ទៅទិញម៉ូតូស្កូភី* (scoopy) *ក្នុងតម្លៃ ២៨៥០$ មានន័យថា លុយ ២៨ ៥០$ បានចេញពីដែនកម្មសិទ្ធិរបស់នាង ហើយៗវាត្រូវវិលចូលទៅក្នុងដែនកម្ម សិទ្ធិរបស់អ្នកលក់។ នេះមានន័យថាលុយ២៨៥០$ នេះគឺជាកម្មសិទ្ធិរបស់អ្នកលក់ម៉ូតូ លែងជាកម្មសិទ្ធិរបស់រតនាទៀតហើយ។ រតនានៅសល់លុយតែ ៥០$ ប៉ុណ្ណោះ ដែលជាកម្មសិទ្ធិរបស់នាង ហើយលុយ៥០$ នេះក៏មិននៅបិតថេរជាមួយនាងរហូតដែរ ប្រសិនបើនាងត្រូវទិញអ្វីផ្សេងទៀត។ នេះជាឧទាហរណ៍តូចមួយដែលបង្ហាញឱ្យឃើញពីអ្វីមួយ មិនបិតនៅជានិរន្តជាមួយនឹងអ្វី*

មួយផ្សេងទៀត ឬជាកម្មសិទ្ធិយ៉ាងផ្តាច់មុខរបស់អ្វីមួយឬរបស់បុគ្គលណាម្នាក់នោះឡើយ។ អ្វីមួយបិតនៅជាមួយនឹងអ្វីមួយផ្សេងទៀត ឬនៅជាមួយបុគ្គលណាម្នាក់ក្នុងលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះរួចហើយវាក៏ផ្លាស់ប្តូរពីអ្វីមួយឬបុគ្គលម្នាក់នោះទៅអ្វីមួយឬបុគ្គលផ្សេងៗទៀតជាដរាបហូរហែគ្មានទីបញ្ចប់ ពេលពេលវេលាសមស្រប របស់វាមកដល់។ ការណ៍ដែលនរណាម្នាក់ប្រកាន់ខ្ជាប់ថា អ្វីមួយគឺជារបស់ខ្លួន យ៉ាងផ្តាច់មុខនោះ ៗវាគឺជាគំនិតមាយាការ (illusion) ដែលមានប្រភពមកពី **អវិជ្ជា** នេះឯង។ យ៉ាងណាមិញ **គំនិត** ដែលនាំទៅដល់ **ចលនាជាតិនិយមនេះ** ក៏ជា **គំនិត មាយាការ** ដែរដែលប្រកាន់ខ្ជាប់ថាជាតិនេះគឺជាជាតិរបស់ខ្លួន ជាទឹកដីកំណើតរបស់ខ្លួន ហើយដែលគ្មានអ្នកណាម្នាក់ ឬជាតិណាមួយអាចហ៊ានមកប៉ះពាល់បានឡើយ។ បន្តិចម្តងៗគំនិតនេះបានដឹកនាំទៅដល់ **គំនិតជាតិនិយមជ្រុល** ដែលគិតហួងហែងតែអំពីជាតិខ្លួន មើលស្រាលលើជាតិដទៃ រួចហើយក៏គិតប្រឹងតែពីអភិវឌ្ឍនិងពង្រីកទឹកដីជាតិរបស់ខ្លួនដែលធ្វើឱ្យប៉ះពាល់ដល់ជាតិដទៃ ដែលនាំឱ្យកើតជម្លោះប្រដាប់អាវុធកាប់សម្លាប់គ្នា រហូតមកដល់សព្វថ្ងៃនេះ។ តើគំនិត និង ចលនាជាតិនិយមនេះគឺជាអ្វី?

## ២. គំនិតជាតិនិយម

### ២.១. ន័យនៃជាតិនិយម

ជាតិនិយម (< ជាតិ + និយម) តាមន័យសព្ទភាសាជាតិ "**ជាតិ**" មានន័យថា កំណើត។ ឧទាហរណ៍ ជាតិខ្មែរ ជាតិចិន។ ឯពាក្យ "**និយម**" មានន័យថា សេចក្តីកំណត់, ធម្មតា, ធម្មជាតិ[១]។ តាមន័យសព្ទ ដែលគេនិយមប្រើសព្វថ្ងៃនេះ "**និយម**" គឺជាការប្រកាន់ខ្ជាប់, ការឱ្យតម្លៃ, ការធ្វើ ឬដើរតាម, ការទទួលឬរក្សាទុកជារបស់ខ្លួន។ ឧទាហរណ៍ **ពុទ្ធនិយម** (Buddhism) គឺជាការស្រឡាញ់ពេញចិត្តនិងការប្រកាន់ ខ្ជាប់ទៅតាមការបង្រៀនរបស់ព្រះពុទ្ធ។ **មនោនិយម** (Idealism) គឺជាជំនឿថា **វត្ថុ នានា** (objects) នៅក្នុងលោកនេះគឺជា **គំនិត** (ideas) ដែលមានអត្ថិភាពតែនៅក្នុងគំនិតព្រះ (the mind of God) ឬមនុស្ស ដែលយល់ឃើញពីពួកវាប៉ុណ្ណោះ[២]។ ពាក្យ "និយម" ត្រូវនឹងបច្ច័យបទ (suffix) ពាក្យអង់គ្លេសថា "- ism" មានន័យថា **និយម**។ ឧទាហរណ៍ថា Marx ម៉ាក្ស > Marxism ម៉ាក្សនិយម។ Plato ផ្លេតូ > Platonism ផ្លេតូនិយម។ បើមនុស្សប្រើជា "- ist" > **អ្នក...និយម**។ ឧទាហរណ៍ Marx ម៉ាក្ស > Marxist អ្នកម៉ាក្សនិយម ឬអ្នកកាន់លទ្ធិម៉ាក្ស[៣]។ Aristotle អារីស្តូតល> Aristotelianist

[១] ជួនណាត, *វចនានុក្រមខ្មែរអេឡិចត្រូនិច*, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ជាតិ, និយម

[២] Cambridge Advanced Learner's Dictionary, 3rd ed. p faith, p idealism

[៣] Franklin E. Huffman and Im Proum, *English-Khmer Dictionary,* New Haven and London, Yale University Press, 1977, p 315

អ្នកអារីស្តូថលនិយម ឬអ្នកដើរតាមគំនិត ឬទស្សនវិជ្ជា របស់អារីស្តូថល។ បើនៅក្នុងទស្សនវិជ្ជា ពាក្យ "-ism" អាចមានន័យថា **លទ្ធិ** (doctrine)[៤], **ជំនឿ** (belief)[៥] ឬក៏អាចមានន័យសំដៅទៅដល់ពាក្យ **មនោគមន៍វិជ្ជា** (Ideology)[៦] នេះផង ដែរ។ រីឯពាក្យថា "-ist" អាចឱ្យគេសម្គាល់ថាជា **សាវ័ក** (follower) របស់និកាយទស្សនវិជ្ជា ណាមួយក៏បាន។ ឧទាហរណ៍ Aristotelianist អ្នកអារីស្តូថលនិយម មានន័យថាអ្នកដែលជាសាវ័ករបស់រីស្តូថល។ បើនៅក្នុងបរិបទសាសនាវិញ វាសម្គាល់ថាជា **សាសនិក** ឬ **សាសនិកា**។ ឧទាហរណ៍ Buddhist ពុទ្ធសាសនិក ឬពុទ្ធ សាសនិកា។ Islamist អ៊ីស្លាមសាសនិក ឬអ៊ីស្លាមសាសនិកា។

ហេតុនេះ **ជាតិនិយម** គឺជាការឱ្យតម្លៃឈានទៅលើកតម្កើង **ជាតិសាសន៍ របស់ខ្លួន** ឱ្យខ្ពស់ជាងជាតិសាសន៍ដទៃៗទៀត ដោយសេចក្តីយល់ថា **ជាតិសាសន៍របស់ខ្លួន** មានជាតិកំណើត មានវប្បធម៌ មានភាសា មានសាសនា មានការរស់នៅ ថ្លៃថ្នូរលើសជាតិដទៃៗទៀត ដែលនាំឱ្យអ្នកជាតិនិយម (nationalist) មានគំនិតតស៊ូ ប្តូរជីវិតស្លាប់រស់ ដើម្បីថែរក្សានិងការពារ ក្នុងបុព្វហេតុជាតិមាតុភូមិដ៏ថ្លៃថ្លារបស់ពួកគេ។

តាមន័យសព្ទភាសាអង់គ្លេស **ជាតិនិយម** (nationalism) គឺជាការមានវេទនារម្មណ៍ ស្រឡាញ់និងមោទនភាពខ្លាំងទៅលើប្រទេសជាតិរបស់ខ្លួន។ ការមានវេទនារម្មណ៍ស្រឡាញ់និងមោទនភាពប្រទេសជាតិរបស់ខ្លួនខ្លាំងនេះនាំឱ្យកើតមាននូវ **គំនិតស្នេហាជាតិ** (patriotism)[៧]។

នៅក្នុងទស្សនវិជ្ជានយោបាយ ពាក្យ **ជាតិនិយម** (nationalism) នេះ បើនៅក្នុងទិដ្ឋភាពវិជ្ជមានរបស់វា វាសំដៅ ដោយត្រង់ទៅរកន័យថា ការជាប់ស្អិត ឬ ការបូជាខ្លួន (adherence) ចំពោះ **អត្តសញ្ញាណជាតិ** (national identity) ដែលបានបង្កើតឡើងដោយចរិកលក្ខណៈខុស ប្លែក

---

[៤] ជាសេចក្តីយល់ឃើញ; សេចក្តីប្រកាន់ជំនឿ, ជំនឿ; ការប្រកាន់តាមយោបល់របស់ខ្លួន ឬតាមទម្លាប់; ពិធី, បែបបទ; ការនិយម។ ឧទាហរណ៍ Confuscianism លទ្ធិខុងជឺ ឬខុងជឺនិយម; Materiallism លទ្ធិរូបជាតុ ឬរូបជាតុនិយម។

[៥] ជាវេទនារម្មណ៍មួយថា អ្វីមួយឬនណាម្នាក់ មានតថ (real) និងមានសច្ច (true); ការជឿជាក់ ឬការមានទំនុកចិត្តលើ។

[៦] ជាសំណុំគំនិត ឬជំនឿដែលបង្កើតជាមូលដ្ឋានទ្រឹស្តីសេដ្ឋកិច្ច ឬនយោបាយ ឬសំណុំគំនិត ឬជំនឿដែលបានរៀបចំឡើងដោយក្រុម ឬបុគ្គលណាមួយ។ ឧទាហរណ៍ មនោគមវិជ្ជាម៉ាក្សនិយម, មនោគមន៍វិជ្ជាពួកគហបតី, មនោគមន៍វិជ្ជាសេដ្ឋកិច្ចនិយម, មនោគមន៍វិជ្ជាពួកសេរី, មនោគមន៍វិជ្ជាពួកកុម្មុយនិស្ត។

[៧] *Jonathan* Crowther, *Oxford Advanced Learner's Dictionary of Current English,* Oxford University Press, Oxford New York, 5th Ed, 1995, p 773

គ្នា ដែលជាធម្មតា វាកើតចេញមកពី ***ប្រវត្តិសាស្ត្រ***, ***វប្បធម៌***, ***ភាសា***, និង ***សាសនាជាតិ*** របស់អ្នកណាម្នាក់ៗ ***ជាតិនិយម*** សង្កត់ធ្ងន់ទៅលើ ***សិទ្ធិ*** (rights) របស់ជាតិចំពោះ ***ស្វ័យសម្រេចចិត្ត*** (self-determi-nation) និង ***អធិបតេយ្យភាព*** (sovereignty) ហើយទាមទារឱ្យ***អភិរក្ស វប្បធម៌***របស់ខ្លួនៗ ***អ្នកជាតិនិយម*** (Nationalists) តែងតែអះអាងថា ***តម្លៃ*** និង ***ផលប្រយោជន៍***របស់ជាតិ បើទោះជាបិតនៅក្នុងគ្រាមានគ្រោះមហន្តរាយ ឬវិបត្តិក៏ដោយក៏ត្រូវតែថែរក្សានិងការពារសិទ្ធិរបស់ពលរដ្ឋម្នាក់ៗរបស់ខ្លួនដែរៗ ពលរដ្ឋម្នាក់ៗត្រូវបង្ហាញស្មារតីស្នេហាជាតិ ដោយស្មោះត្រង់ចំពោះជាតិ និងបម្រើគោល បំណងរួមរបស់ខ្លួនៗ

បើនៅក្នុងទិដ្ឋភាពអវិជ្ជមានវិញ ***ជាតិនិយម***ប្រកាន់ខ្ជាប់នូវ***សារៈសំខាន់ គ្មានហេតុផល*** (unreasonable importance) ចំពោះ***តម្លៃសីលធម៌***, ***វប្បធម៌*** និង ***តម្លៃនយោបាយ***របស់ជាតិៗ ការខ្វល់ខ្វាយ ផ្តាច់មុខមួយចំពោះផលប្រយោជន៍របស់ជាតិខ្លួននាំទៅរក ***ភាពងងឹតងងុល*** (blindness) និង ***ការប្រឆាំងគ្នា*** (belligerence) នៅក្នុងការវាយតម្លៃពីតម្លៃនិងផលប្រយោជន៍របស់ជាតិសាសន៍ដទៃ ឬជនជាតិភាគតិច (minorities) ក្នុងជាតិរបស់ខ្លួនៗ ក្នុងន័យនេះ ***ជាតិនិយម*** គឺស្ទើរតែមិនអាចញែកចេញពី***គំនិតស្នេហាជាតិនិយមជ្រុល*** (chauvinism) បាន[៤]ៗ

## ២.២. សាវតារនៃគំនិតជាតិ និយម

តើដំណើររឿងរ៉ាវអំពីគំនិត ដែលនាំឱ្យកើតចេញទៅជា ***ចលនាជាតិនិយម*** នេះបានចាប់កំណើតឡើងតាំងពីពេលណាមក?

បើតាមប្រវត្តិទស្សនវិជ្ជា បានឱ្យយើងដឹងថា នៅពេលមនុស្សចាប់កំណើត ឡើងដំបូងនៅក្នុង***របបកុម្មុយនិស្តបុព្វកាល*** (primitive communistic periods) ពួកគេពុំទាន់ចេះគិត ឬចេះធ្វើអ្វីនៅឡើយទេៗ ពួកគេរស់នៅទៅតាមធម្មជាតិ មិនមានគំនិតធ្វើផ្ទះសម្បែងដើម្បីជ្រកកោន ឬ មានគំនិតប្រមូលយកទ្រព្យសម្បត្តិ ដូចជា គ្រឿងឧបភោគ និងគ្រឿងបរិភោគមកគរទុកសម្រាប់ទុកប្រើប្រាស់និងបរិភោគនោះនៅឡើយទេៗ ទន្ទឹមនឹងនេះដែរ ***គំនិត*** បែងចែកឱ្យទៅជាបក្សពួកនេះបក្សពួកនោះជាតិសាសន៍នេះជាតិសាសន៍នោះពូជអម្បូរនេះឬពូជអំបូរនោះក៏នៅៗឡើយដែរៗ លុះមកដល់ចុង ***របបកុម្មុយនិស្តបុព្វកាល*** នេះ ទើបមាន ***ពន្លកគំនិត*** ឬ ហៅឱ្យចំថា ***ពន្លកទស្សនវិជ្ជា*** បានកើតឡើងៗ ពន្លកទស្សនវិជ្ជានេះត្រូវបានគេរកឃើញនៅក្នុង ***ជំនឿទេវកថា*** (theology) និងនៅក្នុង ***ជំនឿតូតឹម*** (totemism)ៗ រូបរាងពិតរបស់ទស្សនវិជ្ជាបានកើតឡើងនៅពេលដែលមាន ***បំណែងចែកវណ្ណៈ*** និង ***បំណែងចែកពលកម្ម***ៗ ***បំណែងចែកវណ្ណៈ*** និង ***បំណែងចែកពលកម្ម*** នេះកើតឡើង

[៤] Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004 p.455

នៅក្នុង ***របបទាសភាព***។ គឺរបបនេះហើយ ដែលបានបង្កលក្ខខណ្ឌ បរានុម័តិសម្រាប់កំណកំណើតទស្សនវិជ្ជា។ ***ទស្សនវិជ្ជា*** នេះលេចធ្លោឡើងនៅ ***សតវត្សទី៦ មុនគ.ស.***[៩]។

*ដូច្នេះ បើតាមប្រវត្តិទស្សនវិជ្ជាដូចបានរៀបរាប់មកនេះ ទស្សនវិជ្ជាបានកើតឡើងដំបូងដោយចាប់ផ្តើមនៅក្នុង* ***គំនិត ទំនាស់*** (conflicting thoughts) *ទៅលើការបែងចែកវណ្ណៈអំពី* ***ភាពមាន*** (richness) *និង* ***ភាពក្រ*** (poorness) *ពោលគឺរវាង* ***ម្ចាស់ទាសករ*** *(ពួកអភិជន) និង* ***ទាសករ*** *(ពួកអធន) ឬរវាង* ***បញ្ញាពលកម្ម*** *(អ្នកចេះ ដឹង) និង* ***កាយពលកម្ម*** *(អ្នកធ្វើការដោយ កម្លាំងកាយ) នេះឯង។ ចំពោះ* ***គំនិតជាតិ និយម*** *ដែលនាំទៅដល់* ***ចលនាជាតិនិយម*** *ក៏ត្រូវបានគេគិតថាបានចាប់បដិសន្ធិឡើងដោយផ្តើមចេញមកពីគំនិតបែងចែក វណ្ណៈរវាង* ***អ្នកមាន-អ្នកក្រ, អ្នកចេះ-អ្នក ល្ងង់, អ្នកល្អ-អ្នកអាក្រក់*** *នេះដែរ។ គំនិតទំនាស់នេះបានបន្តការតស៊ូជាគូបដិបក្ខជាមួយគ្នានៅទូទាំងប្រវត្តិសាស្ត្រមនុស្សជាតិរហូតមកដល់សព្វថ្ងៃនេះ។ អ្នកដែលកើតគំនិតញែក* ***ភាពមាន*** *ឱ្យដាច់ចេញពី* ***ភាពក្រ*** *ឬ* ***ភាពចេះដឹង*** *ឱ្យដាច់ចេញពី* ***ភាពល្ងង់ខ្លៅ*** *នេះគឺគ្មានកើតចេញពីអ្នកណា ក្រៅពី* ***ពួកបញ្ញាពលកម្ម*** *ដែលជា* ***ពួកបញ្ញាជន*** *ហើយក៏ជា* ***ពួកអ្នកមាន*** *នេះនោះឡើយ។ ឧទាហរណ៍ នៅក្នុងសង្គមក្រិកបូរាណ នៅសម័យផ្លេតូ (៤២៨ - ៣៤៧ មុនគ.ស.) ផ្លេតូឥតបានគិតថា មនុស្សទាំងអស់សុទ្ធតែមានតម្លៃជាមនុស្ស ដូចៗគ្នានោះទេ។ លោកយល់ថា មានតែមនុស្សមួយចំនួនតូចទេដែលមានតម្លៃជាមនុស្ស និងមានសីលធម៌។ រីឯទាសករគឺជាសត្វដែលចេះនិយាយ។ បើពួកគេគឺជាសត្វ ហេតុនេះពួកគេក៏គ្មានសីលធម៌នោះដែរ*[១០]*។*

*គូបដិបក្ខ:* ***ភាពមាន-ភាពក្រ, ភាព មានបញ្ញា- ភាពល្ងង់ខ្លៅ, ភាពល្អ-ភាព អាក្រក់, ភាពមានតម្លៃ-ភាពឥតតម្លៃ*** *មានផ្ទុកនូវគុណភាព, តម្លៃ, និងផលប្រយោជន៍ មិនដូចគ្នាទេ។ គ្រប់ពាក្យនៅខាងដើមគូបដិបក្ខនីមួយៗ សុទ្ធតែមានផ្ទុកនូវគុណ ភាពនិងតម្លៃវិជ្ជមាន ដូចជា* ***មានសារៈ សំខាន់*** (important), ***គួរឱ្យចង់បាន*** (desirable), ***មានន័យ*** (meaningful), ***គួរឱ្យចូលចិត្ត*** (preferable), *មាន* ***ប្រយោជន៍*** (useful), ***គួរឱ្យចាប់អារម្មណ៍*** (interesting) ...*ល*[១១]*។ ឯចំពោះពាក្យខាងចុងនៃគូបដិបក្ខនីមួយៗវិញ សុទ្ធតែមានផ្ទុកនូវគុណភាពនិងតម្លៃ អវិជ្ជមាន ដូចជា*

---

[៩] *ឆយ យីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណ សម័យក្រិក",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ ៤*

[១០] *ឆយ យីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណ សម័យក្រិក",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ ៦៣*

[១១] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p.76 –77

**គ្មានសំខាន់** (unimportant), មិន**គួរឱ្យចង់បាន** (undesirable), **គ្មានន័យ** (meaningless), មិន**គួរឱ្យចូលចិត្ត** (unpreferable) ឥត**ប្រយោជន៍** (useless), **មិនគួរឱ្យចាប់អារម្មណ៍** (uninteresting) ...លៗ

វរាង់គុណភាពនិង់តម្លៃវិជ្ជមាន និង់អវិជ្ជមានទាំងពីរនេះ មនុស្សដែលជាសត្វ មាន**ចិត្ត** (mind) សម្រាប់គិតពិចារណា បានរកឃើញ និងឱ្យតម្លៃជាខ្លាំងទៅលើ គុណភាពនិងតម្លៃវិជ្ជមានជាងគុណភាពនិងតម្លៃអវិជ្ជមាន ពីព្រោះវាគឺជាមូលដ្ឋាន សម្រាប់អត្ថិភាពពិតប្រាកដរបស់គេៗ វា មានឥទ្ធិពលមកលើការគិត, បង្កើតឱ្យមានឥរិយាបថ, ធ្វើឱ្យគោលការណ៍ និងទស្សនៈ របស់គេមានរូបរាងឡើង, ហើយ និងផ្តល់ នូវលក្ខណៈគ្រប់គ្រាន់ចំពោះជម្រើសរបស់ គេៗ ចំណែកឯគុណភាពនិងតម្លៃអវិជ្ជមានវិញ ត្រូវគេនិយាយថា អន់, ថោក, គួរឱ្យស្អប់ខ្ពើម ហើយគេត្រូវតែដកខ្លួន ចេញឱ្យបានកាន់តែឆ្ងាយកាន់តែល្អៗ ហើយមនុស្សដែលមានគុណភាព និង តម្លៃអវិជ្ជមាននេះត្រូវបានគេចាត់ទុកមកនៅត្រឹមកម្រិត **សត្វតិរច្ឆាន** ឬ **សត្វថ្នាក់ទាប** តែប៉ុណ្ណោះៗ

ដូចនេះ គំនិតនៅក្នុងការបែងចែកវណ្ណៈ ឬគំនិតញែកវត្ថុមួយដើម្បីរកឱ្យ ឃើញពីចរិកលក្ខណៈខុសប្លែកគ្នាពីវត្ថុមួយផ្សេងទៀត គឺជាគំនិតបង្កើតឱ្យមាន ទំនាស់រវាងអង្គវត្ថុៗ តាមតថភាព និងសច្ចភាព វត្ថុនានាមិនដូចគ្នានោះឡើយៗ ភាពដូចគ្នានៃអង្គវត្ថុគឺជាភាពខុសគ្នានៃអង្គវត្ថុ វាគឺជាគំនិតត្រឹមត្រូវៗ ប៉ុន្តែបើយើងគោរពទៅតាមគោលការណ៍ញែកនេះ អ្នកមាន និងអ្នកក្រ អ្នកខ្លាតនិងអ្នកល្ងង់មិនអាចចូលគ្នាចុះ និងអាចជួយបំពេញឱ្យគ្នាបានដោយសុខដុមឡើយៗ វាត្រូវដើរផ្ទុយពីគោលគំនិតខ្មែរដែលលើកឡើងថា "អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅដូចសំពៅទូរសំប៉ាន" ហើយៗ

## ៣. ចលនាជាតិនិយម

### ៣.១. ចលនាជាតិនិយមសង្គមអាល្លឺម៉ង់

ដូចមិត្តអ្នកអានជ្រាបស្រាប់មក ហើយថា បំណែងចែកវណ្ណៈគឺជាបុព្វហេតុចម្បងនៃ**គំនិតជាតិនិយម**ៗ តាមក្រិត ក្រមធម្មជាតិ អ្នកមាន ឬអ្នកចេះ គឺជាអ្នក ដែលមានអានុភាព ឬសក្តានុពលភាព ខ្លាំងមកលើអ្នកអ្នកក្រ ឬអ្នកល្ងង់តាមរយៈកម្លាំងកាយ, កម្លាំងទ្រព្យសម្បត្តិ ឬ កម្លាំងបញ្ញា ដោយវិជ្ជមាន ឬដោយអវិជ្ជមានៗ ដោយវិជ្ជមាន មានដូចជាការជួយ ផ្តល់កម្លាំងកាយ ជួយទំនុកបម្រុងសម្ភារៈ គ្រឿងឧបភោគបរិភោគ...លៗ ជួយផ្តល់ កម្លាំងចិត្ត ដូចជាណែនាំឱ្យអ្នកក្រ ឬអ្នក ល្ងង់ មានសេចក្តីសង្ឃឹមនៅក្នុងជីវិត, ជួយ ថែរក្សាការពារពួកគេឱ្យរស់នៅបាន ដោយសេចក្តីសុខនិងសេចក្តីចម្រើន...លៗ ដោយអវិជ្ជមាន មានដូចជា ការកេងប្រវ័ញ្ច លើកម្លាំងញើសឈាមអ្នកក្រ ឬអ្នកល្ងង់ដែលនាំឱ្យការរស់នៅរបស់ពួកគេកាន់

តែក្រទៅៗ កាន់តែលំបាកទៅៗ រហូតដល់ទៅវិនាសអស់ទ្រព្យសម្បត្តិ បាត់បង់ជីវិត បែកបាក់ក្រុមគ្រួសារ និង ឈានទៅដល់វិនាសបាត់បង់អស់នូវជាតិ មាតុភូមិជាទីស្រឡាញ់របស់ខ្លួនៗ បុគ្គលម្នាក់ ឬជាតិមួយដែលមាន ***កម្លាំងអរិយធម៌*** (civilizational power) ខ្លាំង ហើយប្រើឥទ្ធិពលអវិជ្ជាមកលើបុគ្គលឬជាតិទន់ខ្សោយជាងមួយ វាធ្វើឱ្យជម្លោះបង្កទៅជាសង្គ្រាមរវាងបុគ្គលនិងបុគ្គល ឬរវាងជាតិមួយនិងជាតិមួយទៀតកើតឡើងៗ ហើយ បើបុគ្គលម្នាក់ ឬជាតិមួយប្រកាន់គំនិតទៅ តាមច្បាប់ធម្មជាតិ អ្នកខ្លាំងជាអ្នកឈ្នះ អ្នកខ្សោយជាអ្នកចាញ់ និងវង់គ្រោះភ័យន្តរាយ ត្រីធំស៊ីត្រីតូច ឬទឹកឡើងត្រីស៊ីស្រមោច ដល់ទឹកហោចស្រមោចស៊ីត្រីនោះ នេះគឺជាគំនិតបង្កើតឱ្យមានការតស៊ូរវាងបុគ្គលនិងបុគ្គល រវាងជាតិមួយនិងជាតិមួយ ដែលនាំទៅដល់ការបំផ្លាញគ្នាគ្មានទីបញ្ចប់ រហូតដល់រលាយផែនដីសូន្យអស់ ដែលជាចុងក្រោយ គឺគ្មានពូជសាសន៍ ណាអាចនៅមានអត្ថិភាពបានឡើយៗ បុគ្គលម្នាក់ ឬជាតិមួយដែលធ្លាប់តែខ្លាំង និង បុគ្គលម្នាក់ឬជាតិមួយ ដែលធ្លាប់តែ ខ្សោយនឹងត្រូវតស៊ូជាមួយគ្នាជាដរាបៗ ដល់ដំណើរប្រែប្រួលនៃពេលវេលាឈានចូលមកដល់ ជាតិមួយដែលធ្លាប់តែខ្លាំងក៏ធ្លាក់ទៅជាខ្សោយ ជាតិមួយដែលធ្លាប់តែខ្សោយក៏ប្រែទៅជាខ្លាំង ត្រូវតស៊ូ នៅក្នុងគំនិតសងសឹកដណ្ដើមឈ្នះចាញ់ ដើម្បីដណ្ដើមយកអានុភាពលើគ្នាទៅវិញទៅមកៗ

អ្នកចាញ់ត្រូវបាត់បង់ទឹកដី, បាត់ ជាតិសាសន៍ ពូជអំបូរ, បាត់បង់ភាសា ប្រពៃណី ទំនៀមទម្លាប់ជាទីស្រឡាញ់ របស់ខ្លួនៗ ដោយសារសេចក្តីស្រឡាញ់ នេះទើប ***ចលនាជាតិនិយម*** ក៏បានកើត ឡើងៗ បើដូច្នេះ មនុស្សមិនអាចរស់នៅជាមួយគ្នាដោយប្រើប្រាស់ច្បាប់ធម្មជាតិបានឡើយៗ

នៅក្នុងសង្គមអាល្លឺម៉ង់ដែលដឹក នាំដោយ ***អេដុល្ហ ហ៊ី ត្លែរ*** (Adolf Hitler ១៨៨៩-១៩៤៥) គាត់បានសម្លាប់ ***ជន ជាតិជ្វីហ្វ*** (the Jewish people) អស់រហូតដល់ ទៅជាង៦ លាននាក់ រឿងនេះក៏មកពីមូលហេតុសងសឹកនៅក្នុងរឿងជាតិយមជាមួយជាមួយនឹង ***ជនជាតិជ្វីហ្វ*** ដែលសព្វថ្ងៃជា ***ជនជាតិអ៊ីស្រាអែល*** (Israel people) ដោយមានមូលហេតុដូចខាងក្រោមៈ

***ដើមហេតុទី១*** បណ្ដាលមកពីកាល នៅជាយុវវ័យកំពុងសិក្សា ***ហ៊ីត្លែរ*** មានចំណង់ចំណូលចិត្តទៅលើ ***មុខវិជ្ជាសិល្បៈ*** ប៉ុន្តែ គ្រឹះស្ថានសិក្សានៅទីក្រុង ***វីយែន*** (Vienna) ប្រទេសអូទ្រីស ដែលគ្រប់គ្រង ដោយជនជាតិជ្វីហ្វមិនព្រមទទួលយកលោកឱ្យចូលរៀននោះឡើយៗ ***ដើមហេតុ ទី២*** ក្រោយពេលលោកបរាជ័យមិនបានចូលរៀន ***មុខវិជ្ជាសិល្បៈ ហ៊ីត្លែរ*** បានទៅស្នាក់អាស្រ័យនៅផ្ទះជួលមួយដែលមានម្ចាស់ផ្ទះ ជាជនជាតិជ្វីហ្វ ដែលមានចរិកក្អេងក្អាង ចូលចិត្តមាក់ងាយអ្នកដទៃ រួមទាំង ***ហ៊ីត្លែរ*** ខ្លួនឯងនេះផងៗ ***ដើមហេតុ ទី៣*** នៅក្នុងឆ្នាំ ៨៩៨៧ អាល្លឺម៉ង់អូទ្រីស ជនជាតិជ្វីហ្វអម្បូរ

ជ្វីហ្វអន្តោប្រវេសន៍ ភាគច្រើនគឺជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយក៏ជាអ្នកគ្រប់គ្រងក្តោបក្តាប់លើសេដ្ឋកិច្ចមួយភាគធំនៅក្នុងសង្គម ខណៈពេលដែលជនជាតិម្ចាស់ស្រុកបែរជាក្រតោកយ៉ាក ត្រដាបត្រដួសទៅវិញ។ **ហ៊ីត្លែរ** និងជនជាតិអាល្លឺម៉ង់អូទ្រីសដទៃ ទៀតបានទទួលរងនូវការមើលងាយ មើលថោកជារឿយៗពីសំណាក់ជនជាតិ ជ្វីហ្វអន្តោប្រវេសន៍។ **ដើមហេតុទី៤ ហ៊ីត្លែរ** មានរឿងដ៏សែនខ្លោចផ្សាមួយពាក់ព័ន្ធទៅនឹងម្តាយលោកមានជំងឺមហារីកសុដន។ គាត់ស្លាប់បាត់បង់ជីវិត នៅមន្ទីរពេទ្យដោយសារតែការធ្វេសប្រហែសរបស់ក្រុមគ្រូពេទ្យជាជនជាតិ ជ្វីហ្វ។ មរណភាពរបស់ម្តាយ **ហ៊ីត្លែរ** បានធ្វើឱ្យកំហឹងគុំគួនរបស់យុវជនរូបនេះកាន់តែពុះកញ្ជ្រោលខ្លាំងឡើងចំពោះអម្បូរជនជាតិជ្វីហ្វ។ **ដើមហេតុទី៥** គឺជាមូលហេតុមួយទៀតដែលសៀវភៅជាច្រើនបានលើកឡើងពី**ហ៊ីត្លែរ**ដែលមានការខឹងសម្បារជាមួយនឹងជនជាតិជ្វីហ្វ ដែលមានបំណងចង់បម្លែងប្រទេសអាល្លឺម៉ង់ ទៅជាប្រទេសជនជាតិជ្វីហ្វ[១២]។

មូលហេតុដូចបានរៀបរាប់មកនេះ នៅពេលដែល **ហ៊ីត្លែរ** បានឡើងធ្វើជាមេដឹកនាំនៅប្រទេសអាល្លឺម៉ង់ ការសងសឹកចំពោះជនជាតិជ្វីហ្វ និងបុព្វហេតុជាតិនិយមក៏កើតមានជាហូរហែរហូតដល់ធ្វើឱ្យជនជាតិនេះវិនាសបាត់បង់ជីវិតអស់រហូតដល់ទៅជាង៦ លាននាក់។

### ៣.២. ចលនាជាតិនិយមនៅអាស៊ី

សង្គ្រាមលោកលើកទី២បានចាប់ផ្តើមនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩ ហើយបានបញ្ចប់ទៅវិញនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥។ សង្គ្រាមនេះបានបញ្ឆេះឡើង ដោយមហិច្ឆតារបស់ **ប្លុកយោធាឈ្លានពាន អាល្លឺម៉ង់-អ៊ីតាលី-ជប៉ុន** ឬ **សម្ព័ន្ធភាពត្រីភាគីប៊ែរឡាំង-រ៉ូម-តូក្យូ** មានពួកហ្វាស៊ីស អ៊ីតាលី, ណាស៊ីអាល្លឺម៉ង់, និងយោធានិយមជប៉ុន ដែលជាប្លុកថ្មីក្រោយសង្គ្រាម លោកលើកទី១ ដែលមានបំណងចង់ត្រួតត្រាលើពិភពលោកខាងផ្នែកសេដ្ឋកិច្ច, កម្លាំងយោធា, និងភូមិសាស្ត្រនយោបាយ ហើយដែលក្រោយមកប្លុកយោធាថ្មីនេះ ត្រូវប្រឈមមុខកាន់តែស្រួចស្រាវទល់នឹងអតីតមហាអំណាចចាស់ៗមាន អង់គ្លេស, បារាំង, សហភាពសូវៀត, និងសហរដ្ឋអាមេរិក[១៣]។ សង្គ្រាមនេះបានបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ប្រទេសជាច្រើននៅក្នុងពិភពលោក ទាំងជីវិតមនុស្ស, ទ្រព្យសម្បត្តិ, ហេដ្ឋារចនាសម្ព័ន្ធ, ទាំងទឹកដី, ពូជសាសន៍ភាសា...ល។ ដែលមកដល់ពេលនេះ ប្រទេសមួយចំនួននៅតែបន្តរងគ្រោះដោយសារតែពួកអាណានិគមរបស់ពួកមហាអំណាចអឺរ៉ុបដែល

---

[១២] YouTube, Share Knowledge (SK), February 8, 2017, *ហេតុអ្វីហ៊ីត្លែរសម្លាប់ជនជាតិជ្វីហ្វអស់ជាង ៦ លាននាក់?*

[១៣] គរុនិស្សិតប្រវត្តិវិទ្យាជំនាន់២១, *ប្រវត្តិសាស្ត្រសកលលោក*, វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ?, ទំព័រ ១

បានពុះជ្រៀកទឹកដីរបស់ពួកគេឱ្យទៅជាចម្រៀកៗដើម្បីបែកគ្នាត្រួតត្រា ដែលនាំឱ្យបាត់បង់ជាតិមាតុភូមិជាទីស្រឡាញ់របស់ពួកគេ។

ទិដ្ឋភាពរង់គ្រោះដូចបានរៀបរាប់មកនេះបានជំរុញឱ្យកើតមានដោយមិនដឹងខ្លួននូវមនោសញ្ចេតនាជាតិនិយម ដែលបានប្រែក្លាយទៅជាចលនាប្រឆាំងពួកអាណានិគមស្បែកសដែលមកពីអឺរ៉ុប ឬពួកអាណានិគមជប៉ុន។ គឺចលនាប្រឆាំងពួកអាណានិគមនេះហើយ ដែលជាបុព្វហេតុមូលដ្ឋាននៃគណបក្ស ឬចលនានយោបាយដែលបានផ្តើមលេចចេញជារូបរាងនៅចុងស.វ.ទី១៩ ដើម ស.វ.ទី២០ នៅតាមបណ្តាប្រទេសអាស៊ីនានា។ គណបក្សឬចលនានយោបាយទាំងអស់នេះមានគោលដៅដើមតែមួយដូចគ្នានោះ គឺ ***ការទាមទារឯករាជ្យ***។ ជាក់ស្តែង បក្សសមាជជាតិឥណ្ឌាបង្កើតឡើងនៅឆ្នាំ១៨៨៥, សមាគមន៍យុវជនពុទ្ធបរិស័ទភូមាបង្កើតឡើងនៅឆ្នាំ១៩០៦, បក្ស គួមីងតុងបង្កើតឡើងនៅឆ្នាំ ១៩១២ នៅ ចិន...ល។

នៅក្នុងចលនាតស៊ូជាតិនិយមនេះ ឥណ្ឌាបានតស៊ូទាមទារឯករាជ្យពីអាណានិគមអង់គ្លេសនៅឆ្នាំ១៩៤៧, ភូមានៅ ឆ្នាំ១៩៤៨, ស្រីលង្កានៅឆ្នាំ១៩៤៨, និង ម៉ាឡេស៊ីនៅឆ្នាំ១៩៥៨។ នៅឥណ្ឌូចិន កម្ពុជាបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣, ឡាវនៅឆ្នាំ១៩៥៤, វៀតណាម នៅឆ្នាំ១៩៥៤។ ដោយឡែកឥណ្ឌូនេស៊ី ទទួលឯករាជ្យពីហូឡង់នៅឆ្នាំ១៩៤៩។ រីឯហ្វីលីពីនក្លាយជាប្រទេសឯករាជ្យពេញលេញនៅឆ្នាំ១៩៤៦[១៤]។

## ៤. ភាពមិនឯករាជ្យនៃគំនិតនិង ចលនាជាតិនិយម

ភាពមិនឯករាជ្យនៃគំនិតនិងចលនាជាតិនិយម មានន័យថា គំនិតនិងចលនាជាតិនិយមមិនអាចប្រព្រឹត្តទៅដោយឯកឯងតែឯងដោយមិនពឹងអាស្រ័យទៅលើជាតិសាសន៍ដទៃបានដោយមានការរីកធំធាត់ និងមានអាយុយូរអង្វែងបាននោះឡើយ។ នេះមានន័យថា គំនិតនិងចលនា ជាតិនិយមអាចមានអត្ថិភាពបាន គឺត្រូវ ពឹងអាស្រ័យជាមួយនឹងជាតិដទៃៗទៀត ទើបវាមានការរីកធំធាត់ និងមាននិរន្តរភាពយូរអង្វែងបាន។ រឿងនេះវាមានតថភាពនិងសច្ចភាពសម្រាប់គ្រប់អង្គវត្ថុទាំងអស់ មិនថាតែគំនិតនិងចលនាជាតិនិយម មួយនេះទេ។ ដូចព្រះរាជសម្ភារ ករិរាជ សតវត្សទី១៧បានចារទុកថា ៖ "ខ្លែងហើរ ដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឱ្យ សុខ ទ្រព្យគង់ដ្បិតស្រី បេះសំបែទុកផ្ទះធំ ស្រណុកដ្បិតភរិយា ជា[១៥]។" ប្តីនឹងប្រពន្ធ,

---

[១៤] ហ្សង់-ហ្វ្រង់ស័រតាន់, មនោសញ្ចេតនាជាតិនិយមនៃប្រជាជាតិអាស៊ីអាគ្នេយ៍, ប្រភពដើមពីនាទីភូមិសាស្ត្រនយោបាយរបស់វិទ្យុបារាំងអន្តរជាតិ ផ្សាយជាខេមរភាសា(rfi), តំណភ្ជាប់ព័ត៌មានវិទ្យុបារាំង៖ http;//km.rfi.fr

[១៥] លាង ហាប់អាន, «*ព្រះរាជសម្ភារ ករិរាជសតវត្សទី១៧*», បោះពុម្ពឡើងវិញដោយលោកស្រី ប៊ុនដន, ភ្នំពេញ, ២០០៥, ទំព័រ ៣០

ប្រៀបដូចអណ្តាតនិងធ្មេញ ពួកវាតែងពឹង
អាស្រ័យគ្នា ទើបមនុស្សអាចរស់បាន ទើបគ្រួ
ស្រករមួយមានកូន មានទ្រព្យ សម្បត្តិស្តុកស្តម្ភ
ទើបមានផ្ទះធំទ្រទំនខ្ពស់បាន។ សម្ងួមួយឆ្នាំង
ដែលឆ្ងាញ់មិនមែន មកពីត្រី ឬអំបិល ឬមកពី
ទឹកតែម្យ៉ាង នោះទេ គឺវាឆ្ងាញ់មកពីភាពប៉ិន
ប្រសប់របស់ចុងភៅដែលចេះផ្សំជាតុទាំងនេះ
ចូលគ្នា ដោយគិតរួមទាំងគ្រឿង អ្នកទទួលទាន
និងទាំងបរិយាកាសមនោរម្យទៀត ផង។ ដូចគ្នា
នេះដែរ ជាតិឬអរិយធម៌របស់ជាតិមួយដែល
ចម្រើនរុងរឿងនិងជឿនលឿនទៅបានគឺមិន
មែនមកពីជាតិទោល ឬជាតិដែលមានពូជសុទ្ធ
ដោយឡែកតែឯងដោយមិនមានទំនាក់ទំនង
ជាមួយនឹង ជាតិសាសន៍ដទៃនោះទេ។ គឺវា
អាស្រ័យទៅលើចំណេះដឹង ឬភាពវ័យឆ្លាត
របស់ជាតិនោះ ដែលមានទម្លាប់បើកទូលាយ
ផ្លូវចិត្ត ចេះបង្កើតទំនាក់ទំនងល្អជាមួយ នឹង
អរិយធម៌របស់ជាតិដទៃ ដែលមានអរិយធម៌
ចម្រើនរុងរឿងនិងចេះទទួល យកហើយនិង
ចេះដាំស្ងួចម្រាញ់គំនិត វប្បធម៌និងសង្គមធម៌
ល្អៗរបស់ជាតិដទៃៗ ទាំងនោះមកផ្សំចូល
ជាមួយនឹងគំនិតវប្បធម៌និងសង្គមធម៌របស់
ជាតិខ្លួន ទើបក្លាយទៅជាអរិយប្រទេសមួយ
បាន។ ជាតិមួយ ដែលចេះអភិវឌ្ឍជាតិ ឬ
អរិយធម៌ជាតិរបស់ខ្លួនឱ្យចម្រើនរុងរឿង និង
ជឿនលឿនតាមដំណើរបែបនេះទៅបាន នេះ
ទើបមានឈ្មោះថាជាជាតិដែលចេះស្រឡាញ់
ជាតិមាតុប្រទេសខ្លួន ឬពោល ដោយខ្លីថា **អ្នក
ស្នេហាជាតិ អ្នកស្រឡាញ់ជាតិ ឬ អ្នកជាតិ
និយម** (nationalists)។ ត្រឹង ង៉ា បានសរសេរថា
“អរិយធម៌របស់ ប្រទេសធំៗ ដែលរីកចម្រើនគឺ
សុទ្ធតែជា ផលរួមនៃអរិយធម៌ជាច្រើនដូច
ជាអរិយធម៌អឺរ៉ុប-អាម៉េរិក-រុស្ស៊ី-ចិន-ជប៉ុនជា
ដើម។[១៦]” សម្តីនេះមានតថភាពនិងសច្ចភាព។
នៅក្នុងសង្គមខ្មែរ អ្វីដែលជារបស់ ខ្មែរសុទ្ធដែល
កើតឡើងដោយដៃខ្មែរសុទ្ធ មុននឹងទទួលយក
គំនិតពីឥណ្ឌាដូចជា ព្រហ្មញ្ញសាសនា ឬព្រះ
ពុទ្ធសាសនា ខ្មែរ មានមូលដ្ឋានជំនឿដើមរបស់
ខ្លួន ដូចជា ជំនឿលើព្រលឹងរបស់អ្នកស្លាប់ទៅ
ហើយមិនសូន្យ ហើយទៅចាប់ជាតិជាថ្មី ហើយ
និងជំនឿតូតឹម (totemism) ដែលខ្មែរជឿថា ខ្លួន
បានបន្តពូជពង្សមកពីសត្វត្រកួត ឬសត្វនាគ
ដូចជាកូនស្រីស្តេចភូជង្គនាគ នៅក្នុងពិធី
មង្គលការត្រង់វគ្គព្រះថោង តោងស្បៃនាងនាគ
ជាដើម។ ជំនឿនេះ នៅមានអត្ថិភាពរហូតមក
ដល់សព្វថ្ងៃ ដែលយើងស្គាល់ថាជាអារក្ស-
អ្នកតា ឬពិធីព្រះថោងតោងស្បៃនាងនាគនេះ
ឯង។ នៅក្នុងន័យនេះ បើខ្មែរមានតែជំនឿ
ដើមរបស់ខ្លួននេះតែម្យ៉ាង ខ្មែរក៏មិនមាន ប្រវត្តិ
ធ្លាប់ជាអ្នកកសាងអរិយធម៌មួយដ៏ រុងរឿងនៅ
សម័យអង្គរ គ្មានប្រាង្គប្រា សាទល្អៗ, គ្មានទីវត្ត
អារាម, គ្មានភាសា, គ្មានអក្សរ (ភាសានិងអក្សរ
បាលី-សំស្ក្រឹត) នេះនោះដែរ។ ហេតុនេះ

---

[១៦] ត្រឹង ង៉ា «*អរិយធម៌ខ្មែរ*», ភ្នំពេញ? បោះពុម្ព
លើកទី៣, ព.ស.២៥១៨/គ.ស.១៩៧៤, ទំព័រ ៧

ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាដែលខ្មែរទទួល យកមកពីឥណ្ឌា គឺជាកម្លាំងចលករបាន ជួយជម្រុញនិងជួយអភិវឌ្ឍគំនិតទស្សនវិជ្ជា ខ្មែរឱ្យសម្បូរបែប ដែលនាំ ឱ្យអរិយធម៌ខ្មែរសម្បូរមែកធាងឡើងដល់កំពូល។

ហេតុនេះ ជាតុសុទ្ធ ឬគុណភាព សុទ្ធ ដូចជា ពូជសុទ្ធ, ខ្មែរសុទ្ធ, ចិនសុទ្ធ, សៀមសុទ្ធ, អង់គ្លេសសុទ្ធ, រុស្ស៊ីសុទ្ធ...ល។ មិនមែនជាធាតុ ឬគុណភាពចម្រើនរុង រឿងនិងជឿនលឿន នោះឡើយ។ រឿងនេះ គេអាចពិនិត្យមើលគូស្រករប្ដីប្រពន្ធ ដែលមានប្រភពមកពីពូជតែមួយ ពេលមានកូន ៗនោះមិនឆ្លាតឡើយ។ កូនដែល ល្អនិងឆ្លាត គឺកូនដែលមានប្រភពមកពីឪពុកម្ដាយមកពីត្រកូលផ្សេងគ្នា ឬកូន កាត់ជាតិដទៃ (កូនកាត់ពីរសាសន៍ ឬបី សាសន៍)។ គំនិតដែលល្អគឺគំនិតដែលចេះ បើកទូលាយផ្លូវចិត្ត (open-mindedness) ទទួលយកគំនិតល្អៗពីគំនិតអ្នកដទៃ។ ដើម្បីអភិវឌ្ឍជាតិមួយឱ្យចម្រើន គេត្រូវ សិក្សារៀនសូត្រពីជាតិចម្រើនដទៃៗ។ នៅក្នុងពិភពលោក សហរដ្ឋអាមេរិកគឺជា ប្រ ទេសមហា អំណា ចធំ ទាំងខាងបច្ចេកវិទ្យា, ទាំងខាងកម្លាំងយោធា, សេដ្ឋកិច្ច, ទឹកដី, និងទាំងខាងចំនួនប្រជាជនច្រើនដែលមានជីវភាពធូធា។ ប្រទេសមហាអំណាចធំមួយនេះក្លាយជាប្រទេសមហាអំណាច ក៏ដោយសារតែប្រទេសនេះចេះបើកទូលា យទទួលយកជនជាតិមកពីគ្រប់ប្រទេសដូចជាអាល្លឺម៉ង់, រុស្ស៊ី, បារាំង, អង់ គ្លេស, ចិន...ល។ ឧទាហរណ៍ **អាល់បឺត អាញស្តាញ** (Albert Einstein) គឺជាកំពូលអ្នកប្រាជ្ញរូបវិទ្យាទ្រឹស្ដីសញ្ជាតិអាមេរិកដើមកំណើតអាល្លឺម៉ង់។ លោកគឺជាបិតា នៃអាវុធនុយក្លេអ៊ែរ ដែលធ្វើឱ្យអាមេរិក ក្លាយទៅជា ប្រទេសមហា អំណា ចខាងសព្វាវុធ។ ក្រុមហ៊ុន **អេបផល** (Apple) របស់ **ស្ទីវចប្ស** (Steve Jobs) ដែលឪពុក របស់លោកគឺជាជនអន្តោប្រវេស្សន៍ជនជាតិសេរី, មហាសេដ្ឋី **ជេហ្វ បេហ្សូស** (Jeff Bezos) ដែល ជាអ្នកបង្កើតក្រុមហ៊ុន **អាម៉ាហ្សូន** ជាជនអន្តោប្រវេស្សន៍មកពីប្រទេស គុយបា (Cuba), ក្រុមហ៊ុន **ហ្គូហ្គល** (Google) អ្នកបង្កើតមានពីរនាក់ ដែល ម្នាក់មានឪពុកម្ដាយគឺជាជនភៀសខ្លួនមកពីសហភាពសូ វៀត, ក្រុមហ៊ុន **ថេស្លា** (Tesla) របស់ **អ៊ីឡូនម៉ាស្ក** (Elon Musk) ដែលលោក **អ៊ីឡូន ម៉ាស្ក** គឺជាជនអន្តោ ប្រវេស្សន៍មកពីអាហ្វ្រិកខាងត្បូង...ល។ ឃើញថា សហរដ្ឋអាមេរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចក៏ដោយសារតែមានក្រុម ហ៊ុនខ្នាតយក្សចំនួន៥០០ក្រុមហ៊ុន ដែលអ្នកបង្កើតពួកវាគឺ៤៥% ហើយដែលជាជនអន្តោប្រវេស្សន៍ ឬក៏ជាកូនរបស់ជនអន្តោប្រវេស្សន៍។

ហេតុនេះ ជាតិមួយមិនអាចមានអត្ថិភាពប្រកបដោយវិបុលភាពដោយឯកពជ្យពីជាតិដទៃបានឡើយ។ ការមាន មោទកភាពជាតិខ្លួនដោយមើលស្រាល លើជាតិដទៃ គឺជាគំនិតធ្វើឱ្យអន់ថយ ដល់ជាតិរបស់ខ្លួន។

## ៥. ទិដ្ឋមានភាពនិងអទិដ្ឋមានភាព នៃគំនិតនិងចលនាជាតិនិយម

គំនិតដែលនាំទៅដល់ចលនាជាតិនិយមនៅក្នុងក្របខណ្ឌ សម្មាទិដ្ឋិ និងសម្មាសង្កប្បដែលបើកទៅរកការឱ្យតម្លៃជាតិរបស់ខ្លួននិងជាតិរបស់អ្នកដទៃគឺជាគំនិតនៃអ្នកជាតិនិយមក្លីស្វាងប្រកបទៅដោយគុណធម៌និងមនុស្សធម៌។ ជាតិខ្លួនក៏ល្អ ជាតិរបស់អ្នកដទៃក៏ល្អ ជាតិខ្លួនក៏រស់ ជាតិរបស់អ្នកដទៃក៏រស់ ពោលគឺ គ្រប់ពូជសាសន៍ទាំងអស់នៅទូទាំងពិភពលោកគឺជាបងប្អូននៅក្នុងដំបូលមហាគ្រួសារ។ ផ្ទុយទៅវិញ គំនិតដែលនាំទៅដល់ចលនា ជាតិនិយមនៅក្នុងក្របខណ្ឌមិច្ឆាទិដ្ឋិ និង មិច្ឆាសង្កប្ប ដែលគេហៅថា **ជាតិនិយមជ្រុល** (ultranationalism) នោះ គឺវាបើកឱ្យមនុស្សគិតទៅរកអំណួតអវិជ្ជាមួយនៅក្នុងក្របខ័ណ្ឌនៃ **ច្បាប់ធម្មជាតិ** (natural law) ថា "ត្រីធំស៊ីត្រីតូច អ្នកណាខ្លាំងអ្នកនោះឈ្នះ ដែលដើរបញ្ច្រាស់ទៅនឹង**ច្បាប់វិចារណញ្ញាណខ្មែរ** (reasoning law) ដែលថា "**អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន**។"

បើតាមបទពិសោធន៍ដែលមនុស្ស បានរស់នៅជាមួយគ្នាដោយប្រកាន់យកគំនិតជាតិនិយមទៅតាម **ច្បាប់ធម្មជាតិ** មនុស្សមិនអាចចែកគ្នារស់បានឡើយ។ សង្គ្រាមរវាងជាតិនិងជាតិ ដែលបញ្ចេះឱ្យ ទៅជាសង្គ្រាមលោកលើកទី១ ទី២ កន្លងមក ហើយដែលនឹងត្រៀមទៅរកសង្គ្រាម លោកលើកទី៣នៅពេលមិនយូរនេះ គឺ សុទ្ធតែបណ្ដាលមកពី **គំនិតអំនួតអវិជ្ជា ជាតិនិយមជ្រុល** ឬ **គំនិតមោទកភាពអវិជ្ជា ជាតិនិយមជ្រុល** នៅក្នុងការចង់គ្រប់គ្រងជាតិមួយឬពិភពលោកទាំងមូលនេះឯង។ បើមេដឹកនាំម្នាក់ៗ, អ្នកនយោបាយឬពលរដ្ឋរបស់ជាតិនីមួយៗគិតតែពីរឿងជាតិនិយមហើយដណ្ដើមយកប្រៀបលើគ្នា ដូចក្នុងសភាពការណ៍សព្វថ្ងៃនេះ រុស្ស៊ីវាយដណ្ដើមយកអ៊ុយក្រែន, អ៊ីស្រាអែល វាយដណ្ដើមយកប្រៀបលើហាម៉ាសប៉ាឡេស្ទីននិងអ៊ីរ៉ង់, សៀមវាយដណ្ដើមវាតទីប្ញូន់យកទឹកដីខ្មែរមិនចេះចប់មិនចេះ ហើយតាំងពីអតីតកាលរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ប្លន់យកទាំងទឹកដី ប្លន់យកទាំងសម្បត្តិវប្បធម៌។ តាំងពីអត់ ទឹកដីរហូតមកដល់មានទឹកដី ហើយព្រ ទាំងមិនដឹងគុណខ្មែរថែមទៀត។ ទង្វើរបស់រុស្ស៊ី អ៊ីស្រាអែល ចោរសៀមឈ្លានពាន គឺជាទង្វើជាតិនិយមជ្រុលដែលគ្មាន ជម្រុញអ្វីក្រៅពីជម្រុញការរីកសាយកាយសព្វាវុធដើម្បីធ្វើសង្គ្រាមសម្លាប់គ្នានោះឡើយ គឺច្បាំងគ្នារហូតដល់រលាយផែនដី សូន្យតែម្ដង។

ហេតុនេះ គំនិតដែលបង្កឱ្យទៅជាចលនាជាតិនិយម ឬជាតិនិយមជ្រុលនេះ មិនមែនជាគំនិតសុខដុមឡើយ ពីព្រោះវា ដឹកនាំទៅរកការញែកជាតិមួយឱ្យខុសប្លែកដាច់ដោយឡែកពីជាតិមួយទៀត ដែលបណ្ដាលឱ្យមានចលនាប៉ះទង្គិចគ្នា រវាងជាតិនិងជាតិ។

## សេចក្តីសន្និដ្ឋាន

គំនិតជាតិនិយមគឺជាចលនាគំនិតទស្សនវិជ្ជាមួយដែលបានកើតឡើងសំដៅថែរក្សានិងការពារជាតិបាតុភូមិរបស់ខ្លួន ឱ្យនៅគង់វង្សជានិរន្តរ៍។ គំនិតនេះមានចំណុចវិជ្ជមានផង និងអវិជ្ជមានផង។ ចំណុចវិជ្ជមានត្រង់វាថែរក្សានិងការពារ ជាតិមាតុភូមិខ្លួនឱ្យនៅគង់វង្ស។ ចំណុចអវិជ្ជមាននៅត្រង់ពាក្យថា "ជ្រុល, ហួសហេតុ, ឬពេក" ដែលគេឱ្យឈ្មោះថា "ជាតិនិយមជ្រុល" ដែលបើកឱ្យជាតិរបស់ខ្លួន ទៅរកក្តីវិនាសអន្តរាយ។ ករណីដូចជា អាល្លឺម៉ង់ជាមួយនឹងជនជាតិជ្វីហ្វ, អាល្លឺម៉ង់, អ៊ីតាលី, និងជប៉ុនដែលរួមគ្នាឈ្លានពានដើម្បីត្រួតត្រាពិភពលោកបានបង្កបង្កើតឱ្យទៅជាសង្គ្រាមលោកលើកទី២ ហើយដែលត្រូវសម្ព័ន្ធមិត្តអាម៉េរិកវាយឱ្យវិនាសហិនហោច។ នៅពេលសព្វថ្ងៃសង្គ្រាមឈ្លានពានរបស់រុស្ស៊ីមកលើអ៊ុយក្រែនសម្លាប់ជីវិតកងទ័ព, ជីវិតប្រជាពលរដ្ឋស៊ីវិលអស់រាប់ម៉ឺននាក់, សង្គ្រាមអ៊ីស្រាអែលជាមួយហាម៉ាសប៉ាឡេស្ទីននិងអ៊ីរ៉ង់ សងសឹកគ្នាក្នុងរឿងដណ្តើមប្រៀបលើគ្នាដើម្បី បំបាត់គ្នាទៅវិញទៅមកនិងជាពិសេសដោយផ្ទាល់ការបង្កសង្គ្រាមឈ្លានពាន ដើម្បីប្លន់យកទឹកដីខ្មែររបស់ជាតិសៀម ប្លន់យកទាំងទឹកដី លួចយកទាំងសម្បត្តិវប្បធម៌ខ្មែរ តាំងពីអតីតកាលរហូតមកដល់សព្វថ្ងៃ ហើយព្រមទាំងមិនដឹងគុណខ្មែរទៀត គឺសុទ្ធតែកើតចេញមកពីគំនិត ជាតិនិយម ឬជាតិនិយមជ្រុលនេះឯង។ ទង្វើឈ្លានពានឈានទៅបំបាត់ជាតិសាសន៍នេះ បង្ហាញឱ្យឃើញពីគំនិតឃោរឃៅព្រៃផ្សៃអមនុស្សធម៌ដែលពិភពលោកមិនអាចអត់ឱនឱ្យបានឡើយ។ ជាតិនិយមទល់នឹងជាតិនិយម វានាំទៅដល់សង្គ្រាមជាតិនិយម ដែលផ្តល់ជាវិបាកអវិជ្ជា គឺការកាប់សម្លាប់គ្នានេះឯង។ ហេតុនេះ វាមិនមានប្រយោជន៍អ្វី ដែលជាតិមួយត្រូវបង្កើតឱ្យមានគំនិតជាតិយមជ្រុលនេះឡើយ។ ពិភពលោកមានទំហំធំទូលាយ វិទ្យាសាស្ត្រកាន់តែរីកចម្រើន បែរជាវិសាលភាពផ្លូវចិត្តរបស់មនុស្សនៃ ជាតិខ្លះកាន់តែរួមតូចចង្អៀតទៅវិញ ដែលធ្វើឱ្យពួកគេពិបាកចែកគ្នារស់បាន។ គំនិតនេះ បើគិតឱ្យស៊ីជម្រៅ គឺគួឱ្យសង្វេក ពីជាតិនោះណាស់។ ពេលនេះជាតិនេះមានកម្លាំងគ្រប់គ្រាន់អាចធ្វើការឈ្លានពានជាតិនោះ ដល់ពេលវេលាប្រែប្រួលទៅ ជាតិនេះដែលធ្លាប់ខ្លាំងនឹងត្រូវចុះខ្សោយថយកម្លាំងនឹងត្រូវជាតិនោះដែលធ្លាប់ខ្សោយប្រែទៅជាខ្លាំងនឹងធ្វើការឈ្លានពានជាតិនេះវិញម្តង។ រឿងនេះប្រព្រឹត្តទៅបែបនេះជាដរាបរហូតដល់រលាយផែនដី។

ហេតុនេះ ជាតិនីមួយៗនៅលើ លោកនេះ ត្រូវវិលទៅរកការបណ្តុះគំនិត និងបង្កើតអំពើមនុស្សធម៌ បើកទូលាយផ្លូវចិត្ត រួមគ្នារស់នៅដោយឱ្យតម្លៃគ្នា រវាងបុគ្គលនិងបុគ្គល និងរវាងជាតិនិងជាតិ គឺជាតម្លៃនៃអំពើមនុស្សធម៌ក្នុងនាមជាមនុស្សជាតិដែលមានអារ្យធម៌ ពីព្រោះ គ្រប់ជាតិសាសន៍នៅក្នុងលោកនេះ សុទ្ធតែស្រឡាញ់ជាតិដូចៗគ្នា។

.

## គន្ថនិទ្ទេស


### I- ស្នាដៃនិពន្ធជាភាសាខ្មែរ

១-គរុនិស្សិតប្រវត្តិវិទ្យាជំនាន់២១, *ប្រវត្តិសាស្ត្រសកលលោក*, វិទ្យាស្ថានជាតិអប់រំ

២- ជួនណាត, *វចនានុក្រមខ្មែរអេឡិចត្រូនិច*, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨

៣-ឆយ យី ហ៊ាង,"ប្រវត្តិទស្សនវិជ្ជា បស្ចឹម ប្រទេសប្រវត្តិទស្សនវិជ្ជា បូរាណសម័យក្រិក", សាកលវិទ្យាល័យភូមិន្ទភ្នំពេញ,១៩៩៤

៤-ត្រឹង ងា «*អរិយធម៌ខ្មែរ*», ភ្នំពេញ? បោះពុម្ពលើកទី៣, ព.ស.២៥១៨/គ.ស.១៩៧៤

៥-លាង ហាប់អាន, «*ព្រះរាជាសម្ភារកវីរជសតវត្ស៍ទី១៧*», បោះពុម្ពឡើងវិញដោយលោកស្រីប៊ុនដន, ភ្នំពេញ, ២០០៥

៦- ហ្សង់-ហ្វ្រង់ស័រតាន់, មនោសញ្ចេតនាជាតិនិយមនៃប្រជាជាតិអាស៊ីអាគ្នេយ៍, ប្រភពដើមពីនាទីភូមិសាស្ត្រនយោបាយរបស់វិទ្យុបារាំងអន្តរជាតិ ផ្សាយ ជាខេមរភាសា(rfi), តំណ ភ្ជាប់ព័ត៌មានវិទ្យុបារាំង៖ http;//km.rfi.fr

### II- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

1- Cambridge Advanced Learner's Dictionary, 3rd ed. p faith, p idealism

2- Franklin E. Huffman and Im Proum, *English-Khmer Dictionary,* New Haven and London, Yale University Press, 1977

3- *Jonathan* Crowther, *Oxford Advanced Learner's Dictionary of Current English,* Oxford University Press, Oxford New York, 5th Ed, 1995

4- Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004

5- ៣- YouTube, Share Knowledge (SK), February 8, 2017, ហេតុអ្វីហ៊ីត្លែរសម្លាប់ជនជាតិជ្វីហ្វអស់ជាង ៦លាននាក់?

6- Venancio B. Ardales, *"Introductory text to philosophy,* 2nd printing, New York, 1974